ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King



ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៧០៧ MOC / M 2005

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពី ស្ថានភាពរោងចក្រកាត់ដេរមួយចំនួននៅកម្ពុជា

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** ចាត់ទុករោងចក្រកាត់ដេរសំលៀកបំពាក់ខាងក្រោម ដែលលែងមានដំណើរការ ហើយកម្មករត្រូវបានបញ្ឈប់ពីការងារថាបាន **បិទទ្វារជាស្ថាពរ** :

**1- CAMBODIA KANDAL PROVINCE MANUFACTURING**
**2- CONCEPT GARMENT CAMBODIA CO., LTD.**
**3- LIEN-I TEXTILES (CAMBODIA) CO., LTD.**
**4- LOYAL CAMBODIA LTD.**

រោងចក្រកាត់ដេរសំលៀកបំពាក់ទាំងនេះនឹងត្រូវលុបចេញពីតារាង MFN/GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូតពណ៌ក្រហម និង ចារថាបានបិទទ្វារ ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននីតិកម្មទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** អគ្គនាយកបច្ចេកទេស, នាយិកាខុទ្ទកាល័យ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *ស ខេង*
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *ហោ ណាំហុង*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ